ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# សេចក្តីជូនដំណឹង
# ស្តីពី
# ការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាជំនាញគណនេយ្យ និងហិរញ្ញវត្ថុ ចំនួន ៣ រូប ដើម្បីបម្រើការងារនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាជំនាញគណនេយ្យ និងហិរញ្ញវត្ថុ សរុបចំនួន ៣ រូប មកបម្រើការងារពេញម៉ោង ដែលត្រូវមានគុណវឌ្ឍិដូចខាងក្រោម៖

- មានបរិញ្ញាប័ត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់ផ្នែក គណនេយ្យ, ហិរញ្ញវត្ថុ ឬធនាគារ
- មានបទពិសោធន៍ការងារពាក់ព័ន្ធ យ៉ាងតិច ២ ឆ្នាំ
- ចេះប្រើប្រាស់កម្មវិធី Microsoft Word & Excel, Powerpoint និង Tools ផ្សេងៗបានល្អប្រសើរ
- ចំណេះដឹងផ្នែកភាសាអង់គ្លេសបានល្អប្រសើរ
- ចេះទំនាក់ទំនង និងអាចធ្វើការងារជាក្រុមបានល្អ
- មានសមត្ថភាពគ្រប់គ្រង និងដោះស្រាយការងារប្រកបដោយភាពច្នៃប្រឌិត, ប្រសិទ្ធភាព និងស្មារតីទទួលខុសត្រូវខ្ពស់
- មានអាកប្បកិរិយាល្អ ពុំធ្លាប់ជាប់ទោសបទឧក្រិដ្ឋ ឬមជ្ឈិម
- ព្រមទទួល និងបំពេញកាតព្វកិច្ច តាមលក្ខខណ្ឌនានា ដែលបានកំណត់ក្នុងលក្ខន្តិកៈ និងបទបញ្ញត្តិ

បុគ្គលិកជាប់កិច្ចសន្យាដែលនឹងត្រូវបានជ្រើសរើស នឹងទទួលបានប្រាក់បៀវត្សមូលដ្ឋានសមរម្យទៅតាមតួនាទីការងារ និងគុណវុឌ្ឍិ និងអាចមានឱកាសក្លាយជាមន្ត្រីរាជការក្នុងក្របខណ្ឌមុខងារសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោយពីទទួលបានការវាយតម្លៃសមិទ្ធផលការងារ និងបានបម្រើការងារក្នុងរយៈពេលកំណត់មួយ ។

បេក្ខជន ឬ បេក្ខនារីត្រូវចូលទៅកាន់ http://career.digitaleconomy.gov.kh រួចស្កេន QR Code ដែលមាននៅលើ Portal ដោយប្រើប្រាស់កម្មវិធី CamDigiKey លើទូរស័ព្ទដៃ ដែលអាចទាញយកបានពី App Store ឬ Play Store ដើម្បីទទួលព័ត៌មានបន្ថែម និងដាក់ពាក្យតាមអនឡាញ។ ការទទួលពាក្យចាប់ផ្តើមពីថ្ងៃជូនដំណឹងនេះរហូតដល់ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០២៤ វេលាម៉ោង ១៧:០០ នាទី។

មានតែបេក្ខជន ឬ បេក្ខនារីដែលជាប់ដំណាក់កាលសម្រាំងជ្រើសរើស (Shortlist) តែប៉ុណ្ណោះដែលនឹងត្រូវអញ្ជើញមកសម្ភាសន៍ផ្ទាល់មាត់។

ថ្ងៃ អង្គារ ៦ រោច ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ មករា ឆ្នាំ២០២៤

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh